ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# បូកសរុបសកម្មភាព និងលទ្ធផលការងារ បង្ការ ទប់ស្កាត់និង បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១១ និងទិសដៅឆ្នាំ២០១២




គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ



**ឯកឧត្តម ស ខេង**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ប្រធានគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តខ្ពស់ការពារប្រជាពលរដ្ឋពីបទល្មើសផ្សេងៗ បង្កឡើងដោយជនឧក្រិដ្ឋដែលប៉ុនប៉ងទាញយកផលប្រយោជន៍ពីការជួញដូរមនុស្ស ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលជាគំរូថ្មីនៃទាសភាពសម័យទំនើប និងបានធ្វើឲ្យមនុស្សជាច្រើនទាំងស្ត្រី ទាំងបុរស ទាំងកុមារ ទទួលរងនូវការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ខាតប្រយោជន៍ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្សមិនអាចទទួលយកបាន ។

រាជរដ្ឋាភិបាលបានបង្កើតយន្តការជាតិពហុវិស័យ ដើម្បីបង្ការទប់ស្កាត់និងបង្រ្កាបការជួញដូរមនុស្សនៅកម្ពុជា នៅមហាអនុតំបន់មេគង្គ និងអន្តរជាតិ ។ យន្តការជាតិដែលហៅថា គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបការជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ) គឺជាការរួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាកម្លាំងសរុប ធនធានសរុប និងវិធានការសរុបពីគ្រប់ស្ថាប័ននិងវិស័យពាក់ព័ន្ធ ដើម្បីជម្រុញប្រសិទ្ធិភាពនៃការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ។ ក្រុមការងារ COMMIT ដែលសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរមនុស្ស នៅក្នុងមហាអនុតំបន់មេគង្គ កិច្ចប្រជុំកំពូលអាស៊ានស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) គម្រោងប្រឆាំងការជួញដូរមនុស្សក្នុងតំបន់អាស៊ី ARTIP និងកិច្ចសហប្រតិបត្តិការជំនួយផ្នែកច្បាប់ឱ្យគ្នាទៅវិញទៅមកលើរឿងក្តីជួញដូរមនុស្ស រវាងប្រទេសនៅក្នុង ASEAN គឺជាយន្តការសំខាន់ៗ សម្រាប់ធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីក្នុងតំបន់ដើម្បីប្រឆាំងការជួញដូរមនុស្ស ។

គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានសម្រេចដាក់ចុះនូវផែនការសកម្មភាពជាតិស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ ជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ។

គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានផ្តោតការយកចិត្តទុកដាក់លើការពង្រីកការយល់ដឹងជាសកលអំពីបញ្ហាជួញដូរមនុស្សឲ្យដល់ប្រជាពលរដ្ឋ ជាពិសេសជនរងគ្រោះ និងងាយរងគ្រោះ ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ រៀបចំឱ្យមានកិច្ចសហប្រតិបត្តិការផ្តល់ព័ត៌មាន និងធ្វើអន្តរាគមន៍ បង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើស ចាប់ជនសង្ស័យបញ្ជូនទៅផ្តន្ទាទោសតាមផ្លូវច្បាប់ ។ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ សហការជាមួយដៃគូពាក់ព័ន្ធបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើរត់ពន្ធមនុស្ស និងបញ្ជាប់ដើម្បីដាក់ជូនក្រុមប្រឹក្សាអ្នកច្បាប់ពិនិត្យបន្ថែមទៀតមុននឹងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និងបញ្ជូនទៅរដ្ឋសភាដើម្បីសុំការអនុម័ត។

ព្រមជាមួយគ្នានេះ ផែនការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គឺជាវិធានការដ៏មានប្រសិទ្ធភាពមួយបន្ថែមទៀត ដើម្បីបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់បទល្មើសគ្រប់ប្រភេទរួមទាំងអំពើជួញដូរមនុស្សនៅមូលដ្ឋាន ព្រមទាំងរក្សាបាននូវសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់ និងផ្តល់ភាពកក់ក្តៅជូនប្រជាពលរដ្ឋ និងបានកៀរគរការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធទាំងរដ្ឋបាលដែនដី អាជ្ញាធរមានសមត្ថកិច្ច កងកម្លាំងប្រដាប់អាវុធ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់និន្នាការនយោបាយទាំងអស់ ឲ្យរួមគ្នាធ្វើជាសំណាញ់សុវត្ថិភាពសង្គមដ៏រឹងមាំនៅមូលដ្ឋាន ។

បើជាយ៉ាងនេះក្តី ក៏បញ្ហាជួញដូរមនុស្សនៅតែបន្តកើតមាននិងកាន់តែស្មុគ្រស្មាញ ដោយលាក់បង្កប់ក្រោមរូបភាពនៃទេសន្តរប្រវេសន៍ការងារ និងរូបភាពបម្លាស់ទីឆ្លងដែនដទៃទៀត ដែលនាំឲ្យមានការលំបាកនិងភាពប្រឈមពាក់ព័ន្ធនឹងផលប្រយោជន៍និងការអនុវត្តវិធានការនានាក្នុងបរិបទខុសគ្នានៃវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងវិសាលភាពនៃច្បាប់ក្នុងប្រទេសប្រភពនិងប្រទេសគោលដៅ ។

ក្នុងនាមគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ខ្ញុំមានមោទនភាពខ្ពស់ចំពោះយន្តការជាតិនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានជម្រុញ និងផ្តល់ការលើកទឹកចិត្តឱ្យបង្កើតជាគណៈកម្មាធិការជាតិនេះ និងសូមថ្លែងអំណរគុណដល់បណ្តាសហគមន៍អន្តរជាតិ អង្គការដៃគូក្នុងស្រុក និងក្រៅប្រទេសទាំងអស់ដែលបានរួមសហការជាមួយរាជរដ្ឋាភិបាល ប្រឆាំងបទឧក្រិដ្ឋដែលគួរឱ្យស្អប់ខ្ពើមនេះ ហើយសង្ឃឹមថាគ្រប់ក្រសួង ស្ថាប័នសង្គមស៊ីវិល ផ្នែកឯកជន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងនៅតែបន្តកិច្ចការនេះដោយមិនធ្វេសប្រហែស មិនបណ្តែតបណ្តោយឱ្យជនល្មើសមានឱកាសប្រព្រឹត្តបទល្មើសបានដោយងាយស្រួល និងបណ្តោយឲ្យបទល្មើសជួញដូរមនុស្សគ្រប់រូបភាព កើតមានឡើងដោយមិនបានយកចិត្តទុកដាក់នោះឡើយ ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់សមាជិកគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ និងលេខាធិការដ្ឋានគ្រប់លំដាប់ថ្នាក់ ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកទាំងអស់នៃគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូក្នុងស្រុក និងអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិដែលបានខិតខំយកអស់កម្លាំងកាយចិត្ត បញ្ញាញាណ រួមកម្លាំងគ្នាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងនៅក្នុងតំបន់រហូតបានទទួលលទ្ធផលគួរឲ្យមោទនៈ ។ ខ្ញុំសូមលើកទឹកចិត្ត ឲ្យបន្តកិច្ចសហការឲ្យកាន់តែរឹងមាំបន្ថែមទៀតដើម្បីសម្រេចគោលដៅរបស់យើងទាំងអស់គ្នា ។

ខ្ញុំសូមជូនពរបវរមហាប្រសើរក្នុងឱកាសឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក ព.ស ២៥៥៦ នេះ សូមនាំមកនូវជោគជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការ ជូនសម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា បងប្អូន ជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួន ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត និងសម្រេចជោគជ័យគ្រប់ភារកិច្ច ។

*សូមអរគុណ !*

# មាតិកា


ទំព័រ

**អារម្ភកថា** ..................................................i - ii

**I- សភាពការណ៍ទូទៅ** ..................................................១-២

**II- លទ្ធផលការងារ ប.ជ.រ.ព.ត** ..................................................២

ក - ការរៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ ..................................................២-៤

ខ - ការងារដឹកនាំសម្របសម្រួល ..................................................៤

គ - ការងារអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ..................................................៧

១- ការងារបង្ការ-ទប់ស្កាត់ ..................................................៧

១.១- ការផ្សព្វផ្សាយដើម្បីបង្ការ ..................................................៧

១.២- ការទប់ស្កាត់ ..................................................៩

២- ការងារការពារ-ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍ ..................................................៩-១១

២.១- ការងារការពារស្តារនីតិសម្បទាជនងាយរងគ្រោះ ..................................................៩

២.២- ការធ្វើសមាហរណកម្ម និងតាមដាន ..................................................៩

២.៣- ការទទួលពលករពីអាជ្ញាធរបរទេស ..................................................១០

២.៣.១- តាមរយៈអាជ្ញាធរបរទេស ..................................................១០

២.៣.២- តាមរយៈមណ្ឌលសំចត ..................................................១០

២.៣.៣- តាមរយៈក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ..................................................១១

៣- ការងារអនុវត្តន៍ច្បាប់ ..................................................១១

៤- ការងារកិច្ចការយុត្តិធម៌ ..................................................១២-១៣

៥- ការងារសហប្រតិបត្តិការអន្តរជាតិ ..................................................១៣-១៥

៦- ការងារកិច្ចការកុមារ ..................................................១៥

ឃ - ការងារលើកកម្ពស់សមត្ថភាព ..................................................១៦-១៩

១- ការបណ្តុះបណ្តាល ..................................................១៦

២- សិក្ខាសាលា ..................................................១៩

**III- ការសន្និដ្ឋាន និងវាយតម្លៃ** ..................................................១៩

ក - ចំណុចខ្លាំង ..................................................១៩-២០

ខ - ចំណុចសេសសល់ ..................................................២០-២១

គ - ការសន្និដ្ឋានវាយតម្លៃ ..................................................២១

**IV- ទិសដៅសម្រាប់ ឆ្នាំ២០១២** ..................................................២១-២២

**V- ឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផល
# ការងារបង្ការ ទប់ស្កាត់ និងបង្រ្កាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១២
# និងទិសដៅ ឆ្នាំ២០១៣

(គិតចាប់ពីថ្ងៃទី២៦/១២/១១ - ២៥/១២/១២)

## I. សាវតា និងស្ថានភាពទូទៅ

គណៈកម្មាធិការជាតិដឹកនាំការបង្រ្កាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ហៅកាត់ថា គ.ជ/ប.ជ.រ.ព.ភ ដឹកនាំដោយ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបំពេញភារកិច្ចយ៉ាងសកម្មតាមការកំណត់ អស់រយៈពេលបីឆ្នាំកន្លងមកហើយ ។ គណៈកម្មាធិការជាតិនេះ មានភារកិច្ចទទួលខុសត្រូវប្រឆាំងការជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធ ពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងពង្រឹងទំនាក់ទំនងសហប្រតិបត្តិការក្នុង ការអនុវត្តរាល់បទដ្ឋានគតិយុត្តរបស់ជាតិ និងអន្តរជាតិនានាដែលពាក់ព័ន្ធ ដើម្បីកាត់បន្ថយ ឈានទៅលុបបំបាត់ការជួញដូរមនុស្ស ។

គណៈកម្មាធិការជាតិនេះ ជាយន្តការជាតិពហុវិស័យដែលប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែងនានារបស់ក្រសួងស្ថាប័នក្នុងរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយអង្គការសង្គមស៊ីវិលក្នុងស្រុក អង្គការអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងផ្នែកឯកជន ដើម្បីធ្វើសកម្មភាពព្រមៗគ្នាតាមមុខសញ្ញារៀងៗខ្លួន ផ្អែកតាមទិសដៅសកម្មភាពជាតិដែលបានកំណត់រៀងរាល់ឆ្នាំ ។

គណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ បានអនុម័តផែនការសកម្មភាពជាតិ ឆ្នាំ២០១១-២០១៣ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវឲ្យអនុវត្តយុទ្ធសាស្រ្តចម្រុះពហុវិស័យ ដោយប្រើប្រាស់នូវកម្លាំងសរុប ធនធានសរុប និងវិធានការសរុប បង្កើនប្រសិទ្ធភាពក្នុងការបង្ការទប់ស្កាត់ ការការពារ និងគាំទ្រជនរងគ្រោះ ការអនុវត្តច្បាប់ និងការផ្តន្ទាទោសជនល្មើស រួមផ្សំនិងការពង្រឹងភាពជា ដៃគូ ពង្រឹងការអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ធានាបាននិរន្តភាពការងារសម្រាប់អនុវត្តឆ្លើយតបទៅនឹងបញ្ហាជួញដូរមនុស្ស ។

ទន្ទឹមនឹងនេះ លេខាធិការដ្ឋានដែលជាសេនាធិការរបស់គណៈកម្មាធិការជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផល និងសមិទ្ធផលជាច្រើន ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិក្នុងកិច្ចការប្រឆាំងការជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ ។ កិច្ចខិតខំប្រឹងប្រែងនេះ ទទួលបានការទទួលស្គាល់ពីមជ្ឈ ដ្ឋានជាតិ និងអន្តរជាតិ ព្រមទាំងការវាយតម្លៃពីសហរដ្ឋអាមេរិកឲ្យប្រទេសកម្ពុជាស្ថិតនៅលំដាប់ថ្នាក់លេខ២ក្នុងសកម្មភាពប្រឆាំងការជួញដូរមនុស្ស រយៈពេល០៣ឆ្នាំជាប់ៗគ្នា (គឺឆ្នាំ២០១០-២០១១ និង ២០១២) ។ លទ្ធផលគួរឲ្យមោទនៈនេះ បានបញ្ជាក់អំពីឆន្ទៈ ការទទួលខុសត្រូវ និងការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រឆាំងនឹង អំពើជួញដូរមនុស្ស។

នៅក្នុងឆ្នាំ២០១២នេះ គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានផ្តោតការយកចិត្តទុកដាក់ ជម្រុញ និងបំពេញបន្ថែមចំណុចខ្វះចន្លោះក្នុងក្របខណ្ឌនៃការអនុវត្ត និងក្នុងក្របខណ្ឌគតិយុត្តិមួយ ចំនួនដូចជា៖

ផ្សារការងារ និងទីផ្សារផលិតផលទាំងក្នុងប្រទេស និងក្រៅប្រទេស ក្នុងគោលបំណងផ្តល់លទ្ធភាព និងជម្រើសជូនប្រជាពលរដ្ឋឲ្យមានមុខរបរ និងមានប្រាក់ចំណូលសមរម្យដោយមិនចាំបាច់ផ្សងព្រេង នឹងគ្រោះថ្នាក់ ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលបានបង្កើតឱ្យមានគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារ ដែលមានលក្ខណៈទូលំទូលាយ ពាក់ព័ន្ធនឹងអភិបាលកិច្ចល្អសម្រាប់ទេសន្តរប្រវេសន៍ ការលើកកម្ពស់សមត្ថភាព ការការពារពលករ និង ដាក់បញ្ចូលទេសន្តរប្រវេសន៍ការងារក្នុងកិច្ចអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលកម្ពុជា បានបើកទូលាយឱ្យមានកិច្ចសហការពីអង្គការដៃគូ និងប្រទេសពាក់ព័ន្ធនានាក្នុងនិងក្រៅតំបន់ រួមគ្នាដោះស្រាយបញ្ហាស្មុគស្មាញនៃឧក្រិដ្ឋកម្មឆ្លងដែន និងបាតុភាពអសកម្មទាំងឡាយ ដែលកើតមានក្នុងសង្គម ។

ព្រមជាមួយគ្នានេះ ផែនការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដឹកនាំអនុវត្តដោយក្រសួងមហាផ្ទៃ ជាវិធានការដ៏មានប្រសិទ្ធភាពសម្រាប់បង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់បទល្មើសគ្រប់ប្រភេទរួមទាំងអំពើជួញដូរមនុស្ស ធានាបាននូវសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងបង្កើតបានជាសំណាញ់សុវត្ថិភាពសង្គមដ៏រឹងមាំនៅមូលដ្ឋាន ។

ច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តិទាំងឡាយ ត្រូវបានបង្កើតឡើង និងជម្រុញអនុវត្ត ដែលក្នុងនោះ ទាំងយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបាននិងកំពុងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រប់ថ្នាក់ និងបំផុសប្រជាពលរដ្ឋឲ្យចូលរួមគោរពទាំងអស់គ្នា ។

កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ ត្រូវបានទទួលការវាយតម្លៃពីសហរដ្ឋអាមេរិក ឲ្យស្ថិតនៅលំដាប់លេខ២ ដដែលដូចឆ្នាំ២០១០ ដែលបញ្ជាក់ពីឆន្ទៈដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើសកម្មភាពប្រឆាំងការជួញដូរមនុស្ស ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងខាងលើនេះ ក៏នៅមានចំណុចដែលត្រូវយកចិត្តទុកដាក់មួយចំនួនទៀត សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០១២ ។

## II- <u>លទ្ធផលការងារ ប.ជ.រ.ព.ភ:</u>

នៅក្នុងឆ្នាំ២០១១កន្លងទៅនេះ សកម្មភាពការងារ ប.ជ.រ.ព.ភ ត្រូវបានបន្តអនុវត្តយ៉ាងសកម្ម ដោយមានការចូលរួម និងសហការពីបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាជាច្រើន ទាំងក្នុងរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងបណ្តាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិដែលមានទិសដៅប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ទើបយើងសម្រេចបានលទ្ធផលដូចខាងក្រោម ៖

### ក- <u>ការងាររៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ:</u>

ក្នុងឆ្នាំ២០១១នេះ លិខិតបទដ្ឋាន និងគោលនយោបាយចំនួន**២៣**ត្រូវបានដាក់ចេញឱ្យប្រើប្រាស់ដើម្បីបំពេញបន្ថែមលើភាពខ្វះចន្លោះក្នុងក្របខ័ណ្ឌគតិយុត្តិ ក្នុងនោះមាន៖

១/ <u>រាជរដ្ឋាភិបាល:</u> បានដាក់ចេញនូវ

- ព្រះរាជក្រមលេខ០១១០/០០១នស/រកម ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ។
- អនុក្រឹត្យលេខ៥៥៤អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម ។

- បានចុះកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋកាតា ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា នាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ ។

- អនុក្រឹត្យលេខ១៩០អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ដែលមានគោលដៅរកទីផ្សារការងារ លើកកម្ពស់ជីវភាពធានាសុវត្ថិភាព លើកកម្ពស់អភិវឌ្ឍន៍ធនធានមនុស្ស និងកាត់បន្ថយភាពក្រីក្រ ។

- សារាចរលេខ១១សរណន ចុះ១៥ ខែតុលា ឆ្នាំ២០១១ ស្តីពីការផ្អាកការជ្រើសរើសបណ្តុះបណ្តាល និងបញ្ជូនពលករជាស្ត្រីជំនួយការមេផ្ទះទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។

២/ <u>គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភៈ</u>

- ផែនការសហប្រតិបត្តិការ ឆ្នាំ២០១១ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ ក្នុងកិច្ចការពារសន្តិសុខ ការបង្ការ ប្រឆាំងឧក្រិដ្ឋកម្ម រក្សាសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ។

- សេចក្តីសម្រេចលេខ០០១/១១ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ស្តីពីការផ្ទេរភារកិច្ចអនុប្រធានអចិន្ត្រៃយ៍ នៃលេខាធិការដ្ឋានថ្នាក់ជាតិ ។

- សេចក្តីជូនដំណឹងលេខ០០២/១១ស.ជ.ណា ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១ ដល់អភិបាលរាជធានី-ខេត្ត អំពីការរៀបចំកញ្ចប់ថវិកាសម្រាប់ប្រើប្រាស់ក្នុងលេខាធិការដ្ឋាន ប.ជ.រ.ព.ភ រាជធានី-ខេត្ត នៅឆ្នាំ២០១២ និងឆ្នាំបន្តទៀត ។

៣/ <u>លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភៈ</u>

- សេចក្តីសម្រេចលេខ០១០/១១ស.ស.រ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណបឋម ចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

៤/ <u>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>

- លិខិតលេខ១២៨៨កប.អក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ ណែនាំដល់ក្រុមហ៊ុនជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេសឱ្យគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

- លិខិតលេខ២១៨៤កប/អក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ណែនាំដល់បណ្តាក្រុមហ៊ុនជ្រើសរើសពលករទៅធ្វើការងារនៅប្រទេសថៃ ឱ្យផ្អាកជាបណ្តោះអាសន្នរាល់ការផ្សព្វផ្សាយ និងការជ្រើសរើសពលករថ្មី ។

- ប្រកាសលេខ២១០ក.ប/ប្រ.ក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមការងារដោះស្រាយពលករទេសន្តរប្រវេសន៍ ។

- ប្រកាសលេខ២៤០ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីលក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មដំឡូងមី ។

- ប្រកាសលេខ២៤១ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការងារកុមារក្នុងមុខរបរនេសាទទឹកសាប ។

- ប្រកាសលេខ២៤២ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការងារកុមារក្នុងមុខរបរកសិកម្ម ។

- ប្រកាសលេខ២៤៣ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីលក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មថ្នាំជក់ ។

- ប្រកាសលេខ២៧៥ក.ប/ប្រ.ក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការធ្វើនិរាករណ៍ប្រកាសដែលអនុញ្ញាតឱ្យក្រុមហ៊ុន T& P Co., Ltd ធ្វើការជ្រើសរើសបណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងព្រះរាជាណាចក្រថៃឡង់ដ៍ ។

៥/ ក្រសួងយុត្តិធម៌:

- សេចក្តីសម្រេចលេខ០១កយសសរ/១១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតអាជ្ញាធរកណ្តាលកម្ពុជា ដើម្បីជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម បត្យាប័ន និងការបញ្ជូនទណ្ឌិត រវាងប្រទេសក្នុងតំបន់ស្ថិតនៅក្រោមយុត្តាធិការនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ។

- ចេញសេចក្តីណែនាំលេខ៨០៨កយ.រប/១១ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ ដល់សាលាដំបូងរាជធានី-ខេត្ត ស្តីពីការប្រមូលទិន្នន័យរឿងក្តីក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្ញើមកក្រសួងយុត្តិធម៌ដើម្បីបូកសរុបដាក់បញ្ចូលក្នុងរបាយការណ៍ថ្នាក់ជាតិ ។

- ចេញសេចក្តីណែនាំលេខ១៤៦១កយ.រប/១១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ដល់សាលាដំបូងរាជធានី-ខេត្ត ឱ្យបង្កើនការយកចិត្តទុកដាក់ជម្រុញលើចំណាត់ការរឿងក្តីពាក់ព័ន្ធករណីជួញដូរមនុស្ស ។

៦/ អគ្គស្នងការដ្ឋាននគរបាលជាតិ:

- ផែនការលេខ០២២ជ.ក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ គោលបំណងលើកកម្ពស់ស្មារតីទទួលខុសត្រូវការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម សំដៅបង្ការ-ទប់ស្កាត់បង្ក្រាបរាល់សកម្មភាពបទល្មើសជាទូទៅ ។

- របាយការណ៍លេខ៥៦៨របក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ស្តីពីវិធានការទប់ស្កាត់ពលករចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ។

- សេចក្តីណែនាំលេខ១១៦០ស.ជ.ណ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ដល់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់ការងារគ្រប់គ្រង និងវិធានការជំនាញប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅតាមមូលដ្ឋាន ។

## ខ- ការងារដឹកនាំសម្របសម្រួល:

ការងារដឹកនាំសម្របសម្រួល សរុបមានចំនួន៨៨លើក ដោយលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ថ្នាក់ជាតិចំនួន១៧លើក ក្រសួងកិច្ចការនារីចំនួន២៦លើក -ក្រុមការងារ COMMIT ចំនួន០៤លើក -ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃលេខាធិការដ្ឋានថ្នាក់ជាតិចំនួន០៣លើក -ក្រុមប្រឹក្សាជាតិដើម្បីកុមារចំនួន០១លើក - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០៥លើក -ក្រសួងទេសចរណ៍០១លើក - ក្រសួងមហាផ្ទៃចំនួន០១លើក និងគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្ត ចំនួន៣០លើក ក្នុងនោះមាន: ការពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅប្រទេស ការតាមដានត្រួតពិនិត្យ និងការពង្រឹងការងារលេខាធិការដ្ឋានគ្រប់ថ្នាក់ឱ្យយកចិត្តទុកដ្ឋានក្នុងការអនុវត្តន៍ភារកិច្ច និងធ្វើការសម្របសម្រួលរាល់ការងារជាទូទៅពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការបង្ការ-ទប់ស្កាត់ បង្ក្រាបបទល្មើស ការជួយសង្គ្រោះជនរងគ្រោះនិងការផ្តន្ទាទោសលើជនល្មើស ។ សកម្មភាពទាំងនោះ មានរាយក្នុងតារាងខាងក្រោម៖

តារាងការងារសម្របសម្រួល

| សម្របសម្រួលដោយ | សកម្មភាព | អ្នកពាក់ព័ន្ធ |
|---|---|---|
| -លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ | -សិក្សាស្រាវជ្រាវផ្លាស់ប្តូរបទពិសោធន៍<br>-ប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០១០<br>-ប្រជុំជម្រុញការងារ<br>-ចុះពង្រឹងនិងគាំទ្រការងារតាមបណ្តាខេត្ត<br><br>-ប្រជុំបូកសរុបការងារឆមាសទី១<br>-កែសម្រួលផែនការសកម្មភាពជាតិ<br>-ដោះស្រាយបញ្ហាតុលាការចោទ<br>-ផ្សព្វផ្សាយសារាចរលេខ១១សរណន<br>-ប្រជុំពិសេសជុំវិញបាតុភាពរិះគន់របស់សមាជិកសភាអាមេរិក<br>-សម្របសម្រួលវេទិកាយុវជន និងកិច្ចប្រជុំអង្គការមិនមែនរដ្ឋាភិបាល<br>-ប្រជុំណែនាំការបូកសរុបរបាយការណ៍ឆ្នាំ២០១១<br>-ការបង្ហាញអំពីកិច្ចសហការ<br>-ប្រជុំរៀបចំផែនការសកម្មភាពការងារ | -ប្រតិភូក្រសួងការបរទេសជប៉ុន<br>-គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ<br>-ក្រុមការងារទាំង០៦ របស់លេខាធិ ការដ្ឋាន<br>-លេខាធិការដ្ឋាន (ខេត្តមណ្ឌលគីរី, សៀមរាប, ស្ទឹងត្រែង, ស្វាយរៀង, បន្ទាយមានជ័យ, ឧត្តរមានជ័យ និងខេត្តកោះកុង)<br>-គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ និង លេខាធិការដ្ឋាន<br>-សមាជិកក្រុមការងារទាំង០៦<br>-ក្រុមការងារអង្គការ World Hope ស្ថានទូត US<br>-TAF/USAID, WVC, IOM, ILO<br>-គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ<br>-ក្រុមការងារលេខាធិការដ្ឋានជាតិ<br>- ក្រុមការងារ COMMIT<br>-ក្រុមការងារទាំង០៦<br>-USAID, MTV Exit, មូលនិធិសូម៉ាលីម៉ម,<br>-អង្គការ WINROCK, CARAM, SISHA, LSCW |
| -ក្រសួងមហាផ្ទៃ | -ប្រជុំជាមួយដៃគូពាក់ព័ន្ធដើម្បីកៀរគរថវិកា អនុវត្តផែនការLEAP | -អង្គការ UNICEF |
| -ក្រសួងកិច្ចការនារី | -ដឹកនាំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីជាស្ត្រីនៃប្រទេស ក្នុងតំបន់អាស៊ីបូព៌ាលើកទី៤ ស្តីពីរបកគំហើញនៃវិបត្តិសេដ្ឋកិច្ច និងដំណើរឆ្ពោះទៅមុខ ដោយបញ្ចូលបញ្ហាទេសន្តរប្រវេសន៍<br>-ពិភាក្សាលើសេចក្តីព្រាងឯកសារពាក់ព័ន្ធបញ្ហាហិង្សាលើកុមារ និងមនុស្សវ័យក្មេង និងបង្កើតក្រុមបច្ចេកចំនួនទេស២៦លើក<br>-ពិនិត្យកែសម្រួលកិច្ចព្រមព្រៀងគម្រោងលើកកម្ពស់សុវត្ថិភាពស្ត្រី<br>-ប្រជុំពិភាក្សារៀបចំទិវាជាតិ១២ធ្នូសម្រាប់ឆ្នាំ២០១១ | -រដ្ឋមន្ត្រីជាស្ត្រីនៃប្រទេសទាំង១២/១៦ ក្នុងអាស៊ីបូព៌ា(អាស៊ានចិននិងជប៉ុន)<br><br>-ក្រសួងសង្គមកិច្ច ក្រសួងពាក់ព័ន្ធ និងអង្គការ UNICEF<br><br>-អង្គការឃែរអន្តរជាតិនៅកម្ពុជា<br><br>-អង្គការសូម៉ាលីម៉ម និងដៃគូពាក់ព័ន្ធ |
| -ក្រុមការងារ COMMIT | -ផែនការសកម្មភាពឆ្នាំ២០១១ ក្នុងមហាអនុតំបន់មេគង្គលើកទី៣<br>-រៀបចំផែនការស្វែងរកការគាំទ្រ<br>-ប្រជុំកែសម្រួលខ្លឹមសារកិច្ចព្រម | -សមាជិក COMMIT<br>-សមាជិកលេខាធិការដ្ឋានប.ជ.រ.ព.ភ<br>-សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ |

| | | |
|---|---|---|
| | ព្រៀងកម្ពុជា-វៀតណាម និងគំរូកំណត់អត្តសញ្ញាណជនរងគ្រោះ<br>-ប្រជុំទ្វេភាគីជាមួយវៀតណាម នៅខេត្តសៀមរាប២ថ្ងៃ | -អង្គការដៃគូអភិវឌ្ឍន៍<br>-សមាជិក COMMIT<br>- មូលនិធិស្ទម៉ាលីម៉ម, UNAIP, UNICEF, ILO, WVC,<br>-សមាជិក COMMIT កម្ពុជា-វៀតណាម |
| ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ | -ប្រជុំចំនួន០២លើក កែសម្រួលកិច្ចព្រមព្រៀងកម្ពុជា-វៀតណាម ស្តីពីលុបបំបាត់ការជួញដូរមនុស្ស | -សមាជិកក្រុម |
| -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | -ប្រជុំរៀបចំផែនការសកម្មភាពឆ្នាំ២០១១-២០១២<br>-ប្រជុំពិភាក្សារៀបចំឯកសារកំណត់អត្តសញ្ញាណជនរងគ្រោះ<br>-ពិភាក្សាផែនការសកម្មភាពកិច្ចសហការឆ្នាំបន្ត<br>-ចុះប្រជុំពិភាក្សាអំពីស្ថានភាពជនរងគ្រោះ<br>-ប្រជុំរៀបចំការអនុវត្ត SOP ធ្វើមាតុភូមិនិវត្តជនរងគ្រោះកម្ពុជា-វៀតណាម ។ | -អង្គការ UNICEF និង USAID<br><br>-អង្គការ The Asia Foundation និង UNODC<br><br>-អង្គការIOM និងអង្គការThe Asia Foundation<br><br>-មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ចំនួន០៨ អង្គការ<br>-UNODC |
| -ក្រសួងទេសចរណ៍ | -ស្វែងយល់លទ្ធផលការងារអំពីសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ | -អង្គការទស្សនៈពិភពលោកអូស្ត្រាលី |
| -ក្រុមប្រឹក្សាជាតិដើម្បីកុមារ | -បានរៀបចំរបាយការណ៍លើកទី១ និងលើកទី២ បញ្ជូនទៅគណៈកម្មាធិការសិទ្ធិកុមានៃអង្គការសហប្រជាជាតិ | -សមាជិកក្រុមប្រឹក្សាជាតិដើម្បីកុមារ |
| -លេខាធិការដ្ឋានខេត្តស្វាយរៀង | -ប្រជុំបូកសរុបលទ្ធផលការងារ ប.ជ.រ.ព.ភ ត្រីមាស និងផែនការ អនុវត្តបន្ត | -សមាជិកលេខាធិការដ្ឋានខេត្ត |
| -លេខាធិការដ្ឋានខេត្តព្រះសីហនុ | -ប្រជុំបូកសរុបលទ្ធផលការងារ ប.ជ.រ.ព.ភ ត្រីមាស និងផែនការអនុវត្តបន្ត | -សមាជិកលេខាធិការដ្ឋានខេត្ត |
| -លេខាធិការដ្ឋានខេត្តបន្ទាយមានជ័យ | -ប្រជុំគណៈកម្មការលុបបំបាត់ពលកម្មកុមារ<br>-ប្រជុំពិភាក្សាដើម្បីត្រៀមរៀបចំប្រារព្ធខួបលើកទី៥ ទិវាជាតិ ១២ធ្នូ | -មន្ទីរពាក់ព័ន្ធក្នុងខេត្ត<br><br>-មន្ទីរពាក់ព័ន្ធក្នុងខេត្ត |
| -លេខាធិការដ្ឋានខេត្តប៉ៃលិន | -ប្រជុំពិភាក្សាដើម្បីត្រៀមរៀបចំប្រារព្ធខួបលើកទី៥ ទិវាជាតិ ១២ធ្នូ | -មន្ទីរពាក់ព័ន្ធក្នុងខេត្ត |
| -លេខាធិការដ្ឋានខេត្តកណ្តាល | -ប្រជុំពង្រឹងការងារក្រុមទាំង៦ចំនួន ០៣លើក | -សមាជិកលេខាធិការដ្ឋាន |
| -លេខាធិការដ្ឋានខេត្តកំពង់ឆ្នាំង | -ប្រជុំពង្រឹងការងារក្រុមទាំង៦ចំនួន ០៤លើក | -សមាជិកលេខាធិការដ្ឋាន |
| -លេខាធិការដ្ឋាន | -ប្រជុំពង្រឹងការងារក្រុមទាំង៦ចំនួន | -សមាជិកលេខាធិការដ្ឋាន |

| | | |
|---|---|---|
| ខេត្តស្ទឹងត្រែង | ០២លើក | |
| -លេខាធិការដ្ឋាន ខេត្តតាកែវ | -ប្រជុំពង្រឹងការងារក្រុមទាំង៦ចំនួន ០៤លើក | -សមាជិកលេខាធិការដ្ឋាន |
| -លេខាធិការដ្ឋាន ខេត្តកំពត | -ប្រជុំពង្រឹងការងារក្រុមទាំង៦ចំនួន ០៥លើក | -សមាជិកលេខាធិការដ្ឋាន |
| -លេខាធិការដ្ឋាន ខេត្តឧត្តរមានជ័យ | -ប្រជុំពង្រឹងការងារក្រុមទាំង៦ចំនួន ០៧លើក | -សមាជិកលេខាធិការដ្ឋាន |

**គ- ការងារអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស:**

**១- ការងារបង្ការ-ទប់ស្កាត់:**

**១.១- ការផ្សព្វផ្សាយដើម្បីបង្ការ:**

ក្នុងឆ្នាំ២០១១កន្លងទៅនេះ លេខាធិការដ្ឋាន ប.ជ.វ.ព.ភ បានពិនិត្យទៅលើការងារផ្សព្វ-ផ្សាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យើងបានសហការជាមួយអង្គការដៃគូដូចមាន: USAID, UNIAP, The Asia Foundation, World Vision Cambodia, UNODC, IOM, CWCC, APLE, ECPAT, Cambodia Chabdai, មូលនិធិសូម៉ាលីម៉ម, សម្ព័ន្ធអង្គការជួយកុមារតាមព្រំដែន Big C, Unicef, MTV Exit បានធ្វើការផ្សព្វផ្សាយជាសាធារណៈ អំពីច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បទដ្ឋាន គោលនយោបាយអប្បបរមា ឧបាយកលជនល្មើស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងគ្រោះថ្នាក់ផ្សេងៗដោយការធ្វើទេសន្តរប្រវេសន៍ការងារ ក្រៅប្រទេសដោយ ប្រថុយប្រថាន ការលុបបំបាត់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរដើម្បីឱ្យបានចូលរៀនសូត្រ និង ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យដល់មន្ត្រីពាក់ព័ន្ធ គ្រូបង្គោល និងប្រជាពលរដ្ឋសរុបចំនួន **៧២៨,០៦០**នាក់ (ស្រី**២៤២,៩១០**នាក់) ព្រមទាំងសម្ភារៈផ្សព្វផ្សាយមាន: ផ្ទាំងរូបភាពតាមរ៉ឺម៉ក ម៉ូតូកង់បីចំនួន**១៥៥**គ្រឿង, ខិតប័ណ្ណចំនួន**២,៦៥០**សន្លឹក, ទស្សនាវដ្តីចំនួន**១,៨០០**ច្បាប់, ប្រតិទិនចំនួន**១០,០០០**សន្លឹក, អាវយឺត ១៥,០០០អាវ, ផ្ទាំងរូបភាពចំនួន**០៥**, ការផ្សព្វផ្សាយធ្វើឡើងក្នុងគោលឱ្យមានការជ្រួតជ្រាបយល់ដឹងជាសាធារណៈ តាមរយៈវិទ្យុ, ទូរទស្សន៍, ផ្ទាំងរូបភាព, ប័ណ្ណព័ត៌មាន, ទស្សនាវដ្តី, ប្រតិទិន, វេទិកានៃទិវា១២ធ្នូប្រឆាំងអំពើជួញដូរមនុស្ស ការប្រគំតន្ត្រីសម្រាប់យុវវ័យ និង កម្មវិធីផ្សេងៗជាច្រើនទៀត ក្នុងនោះ៖

- **លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.វ.ព.ភ ៖**

-បើកវេទិកាផ្សព្វផ្សាយ សរុប បានចំនួន**៤០,២២៦**នាក់ (ស្រី**១៥,១៧០**នាក់) ។

-សហការជាមួយអង្គការ USAID និង The Asia Foundation បោះពុម្ព និងចែកផ្សាយប្រតិទិន **១០,០០០**សន្លឹក ស្តីពីចំណាកស្រុកដោយសុវត្ថិភាពដល់លេខាធិការដ្ឋានរាជធានី-ខេត្ត ដើម្បីផ្សាយបន្តដល់គ្រប់ឃុំ-សង្កាត់ ។

-ប្រជុំជាមួយក្រុមការងារបង្ការ-ទប់ស្កាត់ ដើម្បីរៀបចំជំហានក្នុងការស្វែងរកយុទ្ធសាស្ត្រទប់ស្កាត់ពលករទេសន្តរប្រវេសន៍ខុសច្បាប់ ។

- **ក្រសួងកិច្ចការនារី ៖**

-ផ្សព្វផ្សាយសរុបបានចំនួន**៨,៥៣៥**នាក់ (ស្រី**៥,០៤៧**នាក់) ។

-សហការជាមួយអង្គការIOM ពិភាក្សាលើកិច្ចសហការ **"លើកកម្ពស់ការយល់ដឹងសុវត្ថិភាពក្នុងការធ្វើចំណាកស្រុក"** នៅក្នុងខេត្តព្រៃវែង និងកំពង់ចាម ។

- **ក្រសួងអប់រំ យុវជន និងកីឡា** ធ្វើការផ្សព្វផ្សាយ សរុបបានចំនួន**៩,៨៧៥**នាក់ (ស្រី**៥,៧ ៩០**នាក់) ។

- **ក្រសួងព័ត៌មាន** ធ្វើសន្និសីទសារព័ត៌មាន ក្នុងកម្មវិធីទិវាពលកម្មកុមារអន្តរជាតិ ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងរៀបចំផ្សព្វផ្សាយផ្ទាំងរូបភាព បានចំនួន០៥ផ្ទាំង ស្តីពីការលុបបំបាត់ទម្រង់ពលកម្មធ្ងន់ធ្ងរនៃកុមារ ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផ្សព្វផ្សាយក្នុងរាជធានី-ខេត្ត សរុបបានចំនួន៤៦៨នាក់ (ស្រី១១៨នាក់) ។
- ក្រសួងទេសចរណ៍៖

- សហការជាមួយអង្គការ UNODC លើកវិធានការបង្ការ-ទប់ស្កាត់ទេសចរផ្លូវភេទលើកុមារ ។

- សហការជាមួយអង្គការUNIAPកម្ពុជា បើកកិច្ចប្រជុំ០១លើក រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សាគម្រោងស្រាវជ្រាវពីកត្តាងាយរងគ្រោះចំពោះកុមារដែលលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ ។

- សហការជាមួយអង្គការអ៊ិកផាតកម្ពុជា ផ្សព្វផ្សាយផ្ទាំងរូបភាពតាមរ៉ឺម៉កម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុចំនួន១២០គ្រឿង ដែលមានសារអប់រំដល់ភ្ញៀវទេសចរ "Join us to Protect our Children, Welcome Responsible Tourists" ចូលរួមជាមួយយើងខ្ញុំដើម្បីការពារកុមារ, សូមស្វាគមន៍អ្នកទេសចរដែលមានការទទួលខុសត្រូវ ។

- អង្គការសកម្មភាពដើម្បីកុមារ ផ្សព្វផ្សាយផ្ទាំងរូបភាពតាមរ៉ឺម៉កម៉ូតូកង់បីនៅរាជធានីភ្នំពេញចំនួន**៣៥**គ្រឿង ដែលមានសារអប់រំ "**ចូរយកចិត្តទុកការពារកុមារពីការបៀតបៀនផ្លូវភេទ**" និងបានធ្វើការចែកជូនឯកសារផ្ទត់ ខិតប័ណ្ណ និងអាវយឺត ចំនួន២,៦៥០ ដែលន័យអប់រំ និងខ្លឹមសារ "We're Children. We're no sexual attraction" "*រួមគ្នាការពារសុវត្ថិភាពកុមារ*" ដល់តំបន់ទេចរណ៍ និងតំបន់ផ្សេងៗ ក្នុងខេត្តសៀមរាប ព្រះសីហនុ និងបន្ទាយមានជ័យ ។
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ចែកជូនទស្សនាវដ្តីវិបត្តិមានខ្លឹមសារអប់រំពីអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាចំណាកស្រុក ចំនួន១,៨០០ច្បាប់ ដល់សាធារណជន ។
- អគ្គស្នងការដ្ឋាននគរបាលជាតិ បានចូលរួមផ្សព្វផ្សាយ សរុបបានចំនួន**៣៨,៨២០**នាក់ (ស្រី**២៤,៤៤៤**នាក់) ។
- គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ និងលេខាធិការដ្ឋានរាជធានី-ខេត្ត បានរៀបចំវេទិកា និងធ្វើការផ្សព្វផ្សាយ សរុបបានចំនួន៦៣០,១៣៦នាក់ (ស្រី១៩២,៣៩១នាក់) ។ មានដូចខាងក្រោម៖

| | | |
|---|---|---|
| -ខេត្តកណ្តាល | បានចំនួន៨០,២២៨នាក់ | ស្រី២២,៤៥០នាក់ |
| -ខេត្តស្វាយរៀង | បានចំនួន៣,០៩១នាក់ | នាក់ស្រី១,៤១៨នាក់ |
| -ខេត្តកំពង់ស្ពឺ | បានចំនួន២៥,៩៤៧នាក់ | ស្រី១៦,៤៧២នាក់ |
| -ខេត្តសៀមរាប | បានចំនួន១៤,២៩៥នាក់ | ស្រី៧,០២២នាក់ |
| -ខេត្តបន្ទាយមានជ័យ | បានចំនួន១៣,៣៥៨នាក់ | ស្រី១,១១៥នាក់ |
| -ខេត្តកំពង់ធំ | បានចំនួន១,៣១៨នាក់ | ស្រី៦៤៨នាក់ |
| -ខេត្តព្រះសីហនុ | បានចំនួន៤,៧៨០នាក់ | ស្រី៣,០២៧នាក់ |
| -ខេត្តកោះកុង | បានចំនួន៧៤១នាក់ | ស្រី៥២២នាក់ |
| -ខេត្តពោធិ៍សាត់ | បានចំនួន៦៥,៧០៣នាក់ | ស្រី២៥,១៩០នាក់ |
| -ខេត្តកំពត | បានចំនួន២៧,៦៦៩នាក់ | ស្រី១៥,៥០៣នាក់ |
| -ខេត្តព្រះវិហារ | បានចំនួន៥៩,៧៧៦នាក់ | ស្រី៣៧,១៧៤នាក់ |
| -ខេត្តកែប | បានចំនួន១២៦នាក់ | ស្រី១១៦នាក់ |

-ខេត្តតាកែវ បានចំនួន១៧,៦៧១នាក់ ស្រី៥,៥៤០នាក់
-ខេត្តប៉ៃលិន បានចំនួន១,១៥៦នាក់
-ខេត្តកំពង់ឆ្នាំង បានចំនួន៨៩,១៨៣នាក់ ស្រី១៥,២៤១នាក់
-ខេត្តក្រចេះ បានចំនួន៥២៣នាក់ ស្រី៣៣២នាក់
-ខេត្តស្ទឹងត្រែង បានចំនួន៧៩៦នាក់ ស្រី៣៥៥នាក់
-ខេត្តបាត់ដំបង បានចំនួន៧២០នាក់ ស្រី៤៣០នាក់
-ខេត្តព្រៃវែង បានចំនួន២២៣,០៥៥នាក់ ស្រី៣៩,៧៨៦នាក់ ។

**១.២- ការទប់ស្កាត់:**

នៅក្នុងឆ្នាំ២០១១កន្លងទៅនេះ សមត្ថកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានរួមសហការគ្នាជាមួយស្ថាប័នជំនាញ អង្គការពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អនុវត្តការងារបង្ការ-ទប់ស្កាត់ដោយណែនាំអាជីវកម្មបានចំនួន៥៣១គោលដៅ, ល្បាតឃ្លាំមើលចំនួន៤៥៧គោលដៅ, និងទប់ស្កាត់ប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកឆ្លងដែនខុសច្បាប់បានចំនួន៤,៩២៣នាក់ (ស្រីចំនួន២,៣៥១នាក់) អប់រំមុខសញ្ញារកស៊ីនាំមនុស្សឆ្លងដែនខុសច្បាប់បានចំនួន៦២នាក់(ស្រី១១នាក់) និងអប់រំម្ចាស់គោលដៅអាជីវកម្មបានចំនួន៤៨៣នាក់ (ស្រី២៥៥នាក់) ។

- លេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ៖

| លេខាធិការដ្ឋានខេត្ត: | សកម្មភាពទប់ស្កាត់ | ចំនួនសរុប | ស្រី |
|---|---|---|---|
| -បន្ទាយមានជ័យ | -អប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកឆ្លងដែនខុសច្បាប់<br>-អប់រំមុខសញ្ញានាំមនុស្សឆ្លងដែនខុសច្បាប់<br>-ដល់ទេសន្តរប្រវេសន៍ដែលបញ្ជូនពីថៃ | ៤,៨៣១នាក់<br>១២នាក់<br>២៩០នាក់ | ២,៣២០នាក់<br>០២នាក់ |
| -បាត់ដំបង | -អប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកឆ្លងដែនខុសច្បាប់ | ៤៨នាក់ | ១៧នាក់ |
| -កោះកុង: | -អប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកឆ្លងដែនខុសច្បាប់<br>-អប់រំមុខសញ្ញានាំមនុស្សឆ្លងដែនខុសច្បាប់ | ៤៤នាក់<br>២១នាក់ | ១៤នាក់ |
| -កំពង់ស្ពឺ: | -អប់រំបណ្តាគោលដៅខារ៉ាអូខេ<br>-អាជីវករលក់ទូរស័ព្ទដៃ<br>-អប់រំមុខសញ្ញានាំមនុស្សឆ្លងដែនខុសច្បាប់ | ១២០នាក់<br>០៤នាក់<br>០២នាក់ | ៥៥នាក់ |
| -កំពង់ធំ | -ចុះបិទសេចក្តីណែនាំគោលដៅអាជីវកម្ម | ៥៩ នាក់ | |
| -ព្រៃវែង | -អប់រំមុខសញ្ញានាំមនុស្សឆ្លងដែនខុសច្បាប់ | ១៨នាក់ | ០៥នាក់ |
| -កណ្តាល | -អប់រំមុខសញ្ញានាំមនុស្សឆ្លងដែនខុសច្បាប់ | ០៩នាក់ | ០៤នាក់ |
| -កំពត | -អប់រំគោលដៅ ខារ៉ាអូខេ, សេវាកម្សាន្ត | ៣០០នាក់ | ២០០នាក់ |

## ២- ការងារការពារ-ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍:

### ២.១ ការងារការពារ ស្តារនីតិសម្បទាជនងាយរងគ្រោះ

ក្នុងឆ្នាំ២០១១កន្លងទៅនេះ ស្ត្រីរកស៊ីផ្លូវភេទតាមទីសាធារណៈ ត្រូវបានសមត្ថកិច្ចប្រមូលយកមកណែនាំ និងសង្គ្រោះស្ត្រីរងគ្រោះដោយអំពើជួញដូរផ្លូវភេទតាមផ្ទះបន សរុបបានចំនួន ៤៤០នាក់ ហើយបានប្រគល់ឲ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ដើម្បីផ្ដល់ប្រឹក្សា និងបញ្ជូនអ្នកដែលសម្រេចចិត្តជ្រើសយកការគាំទ្របន្តទៅអង្គការដៃគូ ដើម្បីទទួលបានសេវាស្តារនីតិសម្បទា និងសមាហរណកម្ម ។

- បើប្រៀបធៀបតួលេខឆ្នាំ២០១១ ទៅនឹងឆ្នាំ២០១០ ចំនួនស្ត្រីដែលប្រមូលពីតាមទីសាធារណៈ និងសង្គ្រោះតាមផ្ទះបន មានចំនួន**៤៤០លើ៧៦១**នាក់ គឺ **<u>ថយចុះចំនួន</u>** <u>៣២១នាក់</u>។

## ២.២ <u>ការធ្វើសមាហរណកម្ម និងតាមដានៈ</u>

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានតាមដានជនរងគ្រោះ និងងាយរងគ្រោះដែលធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍ក្នុងរាជធានី-ខេត្តចំនួន០៨ (ព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប បាត់ដំបង បន្ទាយមានជ័យ កំពង់ស្ពឺ និងរាជធានីភ្នំពេញ) មានចំនួន**២១៨**នាក់ក្នុងនោះមានជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទចំនួន៩៥នាក់, ដោយរំលោភបំពានផ្លូវភេទចំនួន៥២នាក់, និងជួញដូរកម្លាំងពលកម្មចំនួន៧១នាក់។

## ២.៣ <u>ការងារទទួលពលករពីអាជ្ញាធរបរទេសៈ</u>

### ២.៣.១- <u>តាមរយៈអាជ្ញាធរបរទេសៈ</u>

ក្នុងឆ្នាំ២០១១នេះការទទួលពលករទេសន្តរប្រវេសន៍ពីអាជ្ញាធរបរទេស បើប្រៀបធៀបទៅនឹងឆ្នាំ២០១០ មានចំនួន**១១៨,៧៩១**លើ**១២៧,០៥៣**នាក់ **<u>ថយចុះចំនួន៨,២៦២នាក់</u>** ស្មើនឹង **៦.៩៦%** ។ តាមច្រកព្រំដែនខេត្តចំនួន០៥គឺ (ខេត្តបន្ទាយមានជ័យ, ប៉ៃលិន, កោះកុង, ឧត្តរមានជ័យ និងខេត្តស្វាយរៀង) ។ ជនទេសន្តរប្រវេសន៍ដែលបានទទួលពីអាជ្ញាធរថៃចំនួន **១១៨,១៣៣**នាក់ (ស្រី**៣៩,០៦៦**នាក់) ក្នុងនោះមានកុមារចំនួន**១២,៥៨៣**នាក់ (កុមារី ៤,៧៨៣នាក់) និងទទួលពីអាជ្ញាធរវៀតណាមចំនួន**៦៥៨**នាក់ (ស្រី**៣៩៦**នាក់) ក្នុងនោះ មានកុមារ**៣៨១**នាក់ (កុមារី២,**១៧**នាក់) ដោយបញ្ជូនតាម ៖

| ច្រកទ្វារអន្តរជាតិ | ចំនួនរួម | ស្រី | កុមារ | កុមារី |
|---|---|---|---|---|
| ប៉ោយប៉ែត(បន្ទាយមានជ័យ) | ១១៨,០០៣ | ៣៩,០០៤ | ១២,៥៨៣ | ៤,៧៨៣ |
| ព្រំ(ប៉ៃលិន) | ៨៤ | ៣១ | | |
| ចាំយាម(កោះកុង) | ២០ | ០៥ | | |
| ជាំស្រងាំ(ឧត្តរមានជ័យ) | ២៦ | ២៦ | | |
| បាវិត-ប្រសមន-ធ្លក (ស្វាយរៀង) | ៦៥៨ | ៣៩៦ | ៣៨១ | ២១៧ |
| **សរុប** | **១១៨,៧៩១** | **៣៩,៤៦២** | **១២,៩៦៤** | **៥,០០០** |

ក្នុងចំនួនពលករទេសន្តរប្រវេសន៍ខាងលើ មានមនុស្សចំនួន**១២,៨៦៣**នាក់ ត្រូវបានអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល០១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ ។ ឆ្លងតាមការ សម្ភាសន៍ពលករម្នាក់ម្តងៗ អាចឲ្យសមត្ថកិច្ចក្តាប់បានអត្តសញ្ញាណមេខ្យល់ ចំនួន**១៩៥**នាក់ (ស្រី**៣៦**នាក់) ដើម្បីជាមូលដ្ឋានស្វែងរក និងគ្រប់គ្រងជំនាញ ឯជនទេសន្តរប្រវេសន៍ ត្រូវបានអប់រំណែនាំឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ និងប្រុងប្រយ័ត្ន ចំពោះល្បិចកលជនខិលខូច ។

### ២.៣.២- <u>តាមរយៈមណ្ឌលសិចតៈ</u>

- ជនរងគ្រោះ និងងាយរងគ្រោះធ្វើមាតុភូមិនិវត្តន៍ និងនីរទេសពីប្រទេសថៃក្នុងឆ្នាំ២០១១ មានចំនួន១៦៥នាក់ (កុមារ៨៩នាក់, កុមារី៤៧នាក់, ស្ត្រី២៤នាក់, បុរស០៥នាក់) ក្នុងនោះមានជនរងគ្រោះដោយអំពើជួញដូរពលកម្មចំនួន១០៤នាក់, និងជនរងគ្រោះដោយជួញដូរផ្លូវភេទ១០នាក់ និងជនងាយរងគ្រោះចំនួន៥១នាក់ ។

២.៣.៣- **<u>តាមរយៈក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ:</u>**

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហការជាមួយអង្គការ IOM ជួយសង្គ្រោះពលរដ្ឋខ្មែរចំនួន៥៨៥នាក់ ដែលបញ្ជូនត្រឡប់ក្នុងស្ថានភាពខុសៗគ្នា និងដែលសង្ស័យថាអាចជាអំពើជួញដូរមនុស្សតាមរូបភាពផ្សេងៗ នៅក្រៅប្រទេសដែលមានដូចខាងក្រោម៖
    - ប្រទេសឥណ្ឌូនេស៊ី ចំនួន០៧នាក់
    - ប្រទេសម៉ាឡេស៊ី ចំនួន២៦នាក់ (ធ្វើការខុសច្បាប់តាមមេខ្យល់)
    - ប្រទេសសឹង្ហបុរី ចំនួន០២នាក់ (កម្មករទូក)
    - ប្រទេសថៃ ចំនួន១៩១នាក់
    - ប្រទេសវៀតណាម ចំនួន៣០៨នាក់
    - ប្រទេសទីម័រខាងកើត ចំនួន០២នាក់
    - ប្រទេសតៃវ៉ាន់ ចំនួន០៤នាក់
    - ប្រទេសចិន ចំនួន០៣នាក់ (នារីខ្មែរ-ជួញដូរតាមវិធីរៀបការ)
    - ប្រទេសអូម៉ង់ ចំនួន១៥នាក់ (កម្មករទូក)
    - ប្រទេសអារ៉ាប៊ីសាអូ្វឌីត ចំនួន០៣នាក់ (នារីខ្មែរ-ជួញដូរតាមវិធីរៀបការ)
    - ប្រទេសម៉ូរីស ចំនួន២៤នាក់ (កម្មករទូក)

៣- **<u>ការងារអនុវត្តន៏ច្បាប់:</u>**

**<u>កិច្ចសហប្រតិបត្តិការបង្ក្រាបបទល្មើសៈ</u>**

ក្នុងឆ្នាំ២០១១កន្លងទៅ ធៀបទៅនឹងឆ្នាំ២០១០ ការបង្ក្រាបបទល្មើសដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស មានចំនួន**១៩៤លើ១៦០ករណី គឺកើន៣៤ករណី ស្មើនឹង២១,២%** ចាប់ខ្លួនជនជាប់សង្ស័យ**២៥៥លើ២៤២**នាក់ **កើន១៣នាក់** ក្នុងនោះមានជនបរទេសចំនួន**២១នាក់ (សញ្ជាតិចិន០៥នាក់, បារាំង០៥នាក់, អាមេរិក០៤នាក់, អង់គ្លេស០៣នាក់, ស្វីស០១នាក់, ស៊ុយអែត០១នាក់, អូស្ត្រាលី០១នាក់ និងសញ្ជាតិហូឡង់០១នាក់)** ។ ក្នុងប្រតិបត្តិការបង្ក្រាបករណីខាងលើសមត្ថកិច្ចសង្គ្រោះជនរង គ្រោះបានចំនួន**១,០៣៤**នាក់ (មានអាយុក្រោម១៥ឆ្នាំចំនួន**១១២**នាក់ អាយុ១៥-១៧ឆ្នាំចំនួន **១០១**នាក់ និងអាយុ១៨ឆ្នាំឡើងមានចំនួន**៨២១**នាក់) ជនរងគ្រោះទាំងអស់ត្រូវបានប្រគល់ឱ្យ មន្ទីរសង្គមកិច្ចចំនួន**៤២២**នាក់ អង្គការមិនមែនរដ្ឋាភិបាលចំនួន**៤២**នាក់ និងគ្រួសារចំនួន**៥៧០**នាក់ ។

❖ <u>តារាងលទ្ធផលកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស និងសង្គ្រោះជនរងគ្រោះឆ្នាំ២០១១</u>

| បទល្មើស | ចំនួនករណី | ចំនួនជនសង្ស័យ | | ចំនួនជនរងគ្រោះ | | | បញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|---|---|---|
| | | | | ក្រោម១៥ឆ្នាំ | ១៥-១៧ឆ្នាំ | ១៨ឆ្នាំឡើង | មន្ទីរសង្គមកិច្ច | អង្គការ | គ្រួសារ |
| ជួញដូរមនុស្ស | ៧១ករណី | ៩៩នាក់ | ស្រី២៨ | ២៨នាក់ | ៩៣នាក់ | ៤៦០នាក់ | ១២៨នាក់ | ១០នាក់ | ៤៤៧នាក់ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| អាជីវកម្មផ្លូវភេទ | ១២៣ករណី | ១៥៦នាក់ | ស្រី៥៦ | ៨៤នាក់ | ០៨នាក់ | ៣៦១នាក់ | ២៩៨នាក់ | ៣២នាក់ | ១២៣នាក់ |
| សរុប | ១៩៤ករណី | ២៥៥នាក់ | ស្រី៨៤ | ១,០៣៤នាក់ | | | ១,០៣៤នាក់ | | |

## ៤- <u>ការងារកិច្ចការយុត្តិធម៌:</u>

នៅក្នុងឆ្នាំ២០១១កន្លងទៅនេះ សាលាដំបូងរាជធានី-ខេត្តបានធ្វើចំណាត់ការលើរឿងក្តីជួញដូរមនុស្ស និងសម្រេចជាលទ្ធផលតាមដំណាក់កាល ដូចមានខាងក្រោម ៖

ក-<u>លទ្ធផលចំណាត់ការបទល្មើសក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅតាមសាលាជម្រះក្តីក្នុងឆ្នាំ២០១១:</u>

ក.១ <u>ចំណាត់ការរបស់អយ្យការ រាជធានី-ខេត្ត:</u>

សរុបមានចំនួន**១៩០**ករណី ជនត្រូវចោទមានចំនួន**២៤៧**នាក់ ដូចមានតារាងខាងក្រោម:

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | ប្រភេទចំណាត់ការ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | បើកការស៊ើបសួរ | ស៊ើបអង្កេតបឋម | កំពុងចាត់ការ | តម្កល់ទុកផតចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | |
| ១៩០ | ១០១ | ៩៦ | ០៦ | ៦៣ | ១៩៤ | ៥៣ | ១៣ | ០ | ៧៣ | ៦២ | ៣២ | ១៨ | ០៥ |
| សរុប | ១៩៧ | | ៦៩ | | ២៤៧ | | ១៣ | | ១៩០ | | | | |

ក.២ <u>ចំណាត់ការរបស់របស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត:</u>

សរុបមានចំនួន**១៧៣**ករណី ជនជាប់ចោទមានចំនួន**១៣៧**នាក់ ដូចមានតារាងខាងក្រោម:

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | | នៅក្រៅឃុំ+គ្មានខ្លួន | | | | ប្រភេទចំណាត់ការ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | នីតិជន | | កំពុងចាត់ការ | ជូនទៅជំរះ | លើកលែងចោទ | ជូនទៅពិនិត្យ | បិទការស៊ើបសួរ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | | | |
| ១៧៣ | ៦៣ | ១២៨ | ០៧ | ៦៧ | ៩០ | ៤៧ | ០៧ | ០ | ៩០ | ២០ | ០៣ | ០២ | ១០៦ | ៥៤ | ០៨ | ០២ | ០៣ |
| សរុប | ១៩១ | | ៧៤ | | ១៣៧ | | ០៧ | | ១១០ | | ០៥ | | ១៧៣ | | | | |

ក.៣ <u>ចំណាត់ការរបស់របស់ចៅក្រមជំរះ រាជធានី-ខេត្ត:</u>

សរុបមានចំនួន**១១២**ករណី ពិរុទ្ធជនដែលត្រូវផ្តន្ទាទោស មានចំនួន**១៨២**នាក់ ដូចមានតារាងខាងក្រោម:

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ប្រភេទចំណាត់ការ | | | | | ផ្តន្ទាទោស |
|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ព្យួរទោសសាកង | ព្យួរទោសធម្មតា | ពិន័យប្រាក់ថែម | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | |
| | ប | ស | ប | ស | | | | | | |
| ១១២ | ១២១ | ៤៣ | ១៧ | ០១ | ១៧ | ០៨ | ០៥ | ០១ | ០១ | ១៨២នាក់ |

ខ- <u>លទ្ធផលចំណាត់ការបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កំណត់ដោយក្រសួងការបរទេសសហរដ្ឋអាមេរិក:</u>

ខ.១ <u>ចំណាត់ការរបស់អយ្យការ រាជធានី-ខេត្ត:</u>

សរុបមានចំនួន០៧ករណី ជនត្រូវចោទមានចំនួន០៨នាក់ ចំណាត់ការលើរឿងក្តី បានចំនួន០៧នាក់ ដូចមានតារាងខាងក្រោម:

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | ប្រភេទចំណាត់ការ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | បើកការស៊ើបសួរ | ស៊ើបអង្កេតបឋម | កំពុងចាត់ការ | តម្កល់ទុកឥតចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | |
| ០៧ | ១១ | ១១ | ០១ | ០១ | ០៨ | ០ | ០ | ០ | ០១ | ០២ | ០២ | ០១ | ០១ |
| សរុប | ២២ | | ០២ | | ០៨ | | ០ | | ០៧ | | | | |

## ខ.២ ចំណាត់ការរបស់របស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត:

សរុបមានចំនួន១០ករណី ជនជាប់ចោទមានចំនួន០៦នាក់ ចំណាត់ការលើរឿងក្តី បានចំនួន១០នាក់ ដូចមានតារាងខាងក្រោម:

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | | នៅក្រៅឃុំ+គ្មានខ្លួន | | | | ប្រភេទចំណាត់ការ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | នីតិជន | | កំពុងចាត់ការ | ជូនទៅជំរះ | លើកលែងចោទ | ជូនទៅពិនិត្យ | បិទការស៊ើបសួរ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | | | |
| ១០ | ០២ | ០៩ | ០ | ០៥ | ០៥ | ០១ | ០ | ០ | ០៥ | ០១ | ០១ | ០ | ០៩ | ០១ | ០ | ០ | ០ |
| សរុប | ១១ | | ០៥ | | ០៦ | | ០ | | ០៦ | | ០១ | | ១០ | | | | |

## ខ.៣ ចំណាត់ការរបស់របស់ចៅក្រមជំរះ រាជធានី-ខេត្ត:

សរុបមានចំនួន១១ករណី ពិរុទ្ធជនដែលត្រូវផ្តន្ទាទោសមានចំនួន២៤នាក់ ដូចមានតារាងខាងក្រោម:

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ប្រភេទចំណាត់ការ | | | | | ផន្ទាទោស |
|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ព្យួរទោសសាល្បង | ព្យួរទោសធម្មតា | ពិន័យប្រាក់ថែម | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | |
| | ប | ស | ប | ស | | | | | | |
| ១១ | ១៦ | ០៨ | ០ | ០ | ០ | ០៤ | ០៤ | ០១ | ០ | ២៤ នាក់ |

## គ- ចំណាត់ការលើរឿងក្តីជួយដល់ជនរងគ្រោះ

កិច្ចសហការរបស់អង្គការធ្វើចំណាត់ការជួយដល់ជនរងគ្រោះលើរឿងក្តីជួញដូរមនុស្ស ដើម្បីជម្រុញឱ្យមានការផ្តន្ទាទោស មានដូចខាងក្រោម ៖

| អង្គការ | ចំនួនករណី | ជនរងគ្រោះ | លទ្ធផលតាមដំណាក់កាល | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | សវនាការរួច | ឧទ្ធរណ៍ | ចៅក្រោមជំរះ | ចៅក្រមស៊ើប | ព្រះរាជអាជ្ញា | នគរបាល | សំណាង |
| ជំនួយផ្លូវច្បាប់ដល់កុមា និងស្ត្រី | ១៣ករណី | ១៩៥ | ០៣ | ០ | ០២ | ០៣ | ០១ | ០៤ | ០ |
| កម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ | ៧៦ករណី | ៧៦ | ០៦ | ០២ | ០ | ០២ | ០ | ០ | ៦៦ |

## ៤- ការងារសហប្រតិបត្តិការអន្តរជាតិ:

ក្នុងឆ្នាំ២០១១កន្លងទៅនេះ យើងបានទៅចូលរួមកិច្ចប្រជុំ និងបំពេញកិច្ចសហប្រតិបត្តិលើ ការងារផ្សេងៗ តាមការអញ្ជើញរបស់បណ្តាប្រទេសមួយចំនួនសរុបចំនួន២៣លើក ក្នុងនោះមាន:

-ក្រសួងមហាផ្ទៃចំនួន០១លើក, ក្រុមការងារ COMMIT ចំនួន០៤លើក, ក្រសួងកិច្ចការនារីចំនួន០២លើក, ក្រសួងសង្គមកិច្ចចំនួន០១លើក, ក្រសួងយុត្តិធមិចំនួន០១លើក, ខេត្តស្វាយរៀងចំនួន០២លើក, ខេត្តក្រចេះចំនួន០១លើក, ខេត្តកណ្តាលចំនួន០១លើក ខេត្តតាកែវចំនួន ០១លើក និងខេត្តកំពតចំនួន០១លើក ដូចមានតារាងខាងក្រោម ៖

| ក្រសួង-ស្ថាប័ន | សកម្មភាពសហប្រតិបត្តិការ | ទីកន្លែង |
|---|---|---|
| -មហាផ្ទៃ | -ប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៤ ស្តីពីការងារប្រយុទ្ធប្រឆាំងទប់ស្កាត់ការរត់ពន្ធ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន<br>-សិក្ខាសាលាស្តីពីកិច្ចការពារកុមារ<br>-បណ្តុះបណ្តាល ស្តីពីការជួញដូរមនុស្ស ការរត់ពន្ធមនុស្សខុសច្បាប់ ការបង្ខំពលកម្មកុមារ ទេសចរផ្លូវភេទលើកុមារ ការស៊ើបអង្កេត និងការទប់ស្កាត់បទល្មើសផ្លូវភេទ<br>-សវនាការបង្ហាញសក្ខីកម្មក្នុងសំណុំរឿងក្តីករណីទិញពេស្យាចារកុមារ នៅប្រទេសកម្ពុជា<br>-បណ្តុះបណ្តាលស្តីពីការជួញដូរមនុស្ស ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>-ប្រជុំលើកទី២ ថ្នាក់ជំនាញពិភាក្សាអំពីលទ្ធភាពចងក្រងអនុសញ្ញា អាស៊ាន ស្តីពីការជួញដូរមនុស្ស ASEAN Convention on Trafficking inpersons (ACTIP)<br>-ប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៥បូក៣ (ចិន ជប៉ុន កូរ៉េ) ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន | -កោះបាលី ប្រទេសឥណ្ឌូនេស៊ី<br>-ប្រទេសវៀតណាម<br>-ប្រទេសថៃ០១លើក<br>-ប្រទេសហ្វីលីពីន០១លើក<br>-ប្រទេសម៉ាឡេស៊ី០១លើក<br>-ទីក្រុង Los Angeles រដ្ឋ California សហរដ្ឋអាមេរិក ០២លើក<br>-ប្រទេសថៃ<br>-ប្រទេសហ្វីលីពីន<br>-កោះបាលី ប្រទេសឥណ្ឌូនេស៊ី |
| -COMMIT | -ប្រជុំលើកទី១០ (GMS) មហាអនុតំបន់មេគង្គ ស្តីពីយុទ្ធនាការលើកកម្ពស់ការយល់ដឹងសម្រាប់ចំណាក<br>-ប្រជុំថ្នាក់តំបន់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការផ្សារភ្ជាប់ទំនាក់ទំនងក្នុងតំបន់អាស៊ី<br>-ប្រជុំមហាអនុតំបន់មេគង្គលើកទី៣ដើម្បីពិភាក្សាឆ្លងផែនការសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស<br>-ប្រជុំការងារ COMMIT គំនិតផ្តួចផ្តើមថ្នាក់តំបន់ និងការងារមួយចំនួនទៀតរបស់ COMMIT | -ប្រទេសឡាវ<br>-ប្រទេសហ្វីលីពីន<br>-ក្រុងបាងកក ប្រទេសថៃ<br>-ក្រុងបាងកក ប្រទេសថៃ |
| -កិច្ចការនារី | -សិក្ខាសាលាតំបន់មេគង្គលើកទី២ ស្តីពីដំណោះស្រាយ របស់ក្រុមការងារចម្រុះក្នុងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>-ពិភាក្សាពីចក្ខុវិស័យ COMMIT រហូតដល់ឆ្នាំ២០១៣ ផែនការសកម្មភាពអនុតំបន់លើកទី៣ (SPAIII) | -ប្រទេសថៃ<br>-ក្រុងបាងកក ប្រទេសថៃ |
| -សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | -ប្រជុំការងារអនុវត្តន៍ បទដ្ឋានប្រតិបត្តិការ SOP កម្ពុជា-វៀតណាម ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ | -ប្រទេសវៀតណាម |
| -យុត្តិធម៌ | -ប្រជុំគណៈកម្មាធិការសម្របសម្រួលនៃគម្រោងតំបន់ | -ក្រុងបាងកក ប្រទេសថៃ |

| | | |
|---|---|---|
| | អាស៊ី(ARTIP) ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សថ្នាក់តំបន់ | |
| -ខេត្តស្វាយរៀង | -ប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការការពារ ទប់ស្កាត់បទល្មើសជួញដូរមនុស្សឆ្លងដែន<br>-ប្រជុំស្តីពីកិច្ចសហប្រតិបត្តិការរួមគ្នាការពារសន្តិសុខ បង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងកាត់ព្រំដែន | -ឡុងអានប្រទេសវៀតណាម<br>-ខេត្តតាយនីញ ប្រទេសវៀតណាម |
| -ខេត្តក្រចេះ | -ប្រជុំដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ លើការងារបង្ការ-ទប់ស្កាត់ ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សរួមគ្នា | -ខេត្តប៊ីញភឿក ប្រទេសវៀតណាម |
| -ខេត្តកណ្តាល | -ប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការបង្ការ-ទប់ស្កាត់ ការជួញដូរមនុស្សរួមគ្នាក្នុងឆ្នាំ២០១១ និងលើកទិសដៅអនុវត្តបន្តនៅក្នុងឆ្នាំ២០១២ | -ខេត្តអាងយ៉ាង ប្រទេសវៀតណាម |
| -ខេត្តតាកែវ | -ប្រជុំដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការបង្ការ-ទប់ស្កាត់ការជួញដូរមនុស្សរួមគ្នាក្នុងឆ្នាំ២០១១ និងលើកទិសដៅអនុវត្តបន្តនៅក្នុងឆ្នាំ២០១២ | -ខេត្តអាងយ៉ាង ប្រទេសវៀតណាម |
| -ខេត្តកំពត | -ប្រជុំដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នាបង្ការ-ទប់ស្កាត់ការជួញដូរមនុស្សឆ្លងកាត់ព្រំដែន | -ខេត្តគៀងយ៉ាង ប្រទេសវៀតណាម |

### ៦- ការងារកិច្ចការកុមារៈ

ក្នុងឆ្នាំ២០០១កន្លងទៅនេះ កិច្ចការពារកុមារយើងបានបំពេញកិច្ចសហការការងារអាទិភាពមួយចំនួនដែលឆ្លើយតបទៅនឹងអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារដែលមានលទ្ធផលសកម្មភាពដូចខាងក្រោម៖

- ក្រុមការងារកិច្ចការកុមារ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ប្រជុំ ពិភាក្សាលើផែនការសកម្មភាពថ្មីក្នុងការអនុវត្តន៍បន្ត ទៅលើកិច្ចការពារកុមារ ។
- ក្រុមប្រឹក្សាជាតិដើម្បីកុមារ បើកកិច្ចប្រជុំដើម្បីពិនិត្យ និងសម្រេចលើសេចក្តីព្រាងរបាយការណ៍អនុវត្តពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។
- អនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារបានបើកកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងជាមួយតំណាង ក្រសួងពាក់ព័ន្ធ បណ្តាខេត្តគោលដៅ សហជីពសមាគមនិយោជិក និងអង្គការសង្គមស៊ីវិល ពិនិត្យពិភាក្សា ស្តីពីគម្លាតនៃក្របខ័ណ្ឌច្បាប់ និងការអនុវត្តន៍ច្បាប់ពាក់ព័ន្ធពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដើម្បីកែសម្រួលឡើងវិញក្នុងការឆ្ពោះទៅសម្រេចគោលដៅភ្លោះ របស់ប្រទេសកម្ពុជា ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាន៖

-ប្រជុំសមាជិកអនុគណៈកម្មការជាតិពលកម្មកុមារប្រចាំត្រីមាសដើម្បីពិភាក្សាវាយតម្លៃពាក់កណ្តាលគម្រោងរបស់អង្គការILO/IPEC អង្គការWINROCK អន្តរជាតិប្រចាំនៅកម្ពុជា ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ដើម្បីសម្រេចគោលដៅភ្លោះរបស់រាជរដ្ឋាភិបាលឆ្នាំ២០១៥ និងគោលដៅសកលឆ្នាំ២០១៦ នៅប្រទេសកម្ពុជា និងបានសហការអនុវត្តយុទ្ធសាស្ត្រដកហូត និងធ្វើការបង្ការ-ទប់ស្កាត់កុមារពីទម្រង់ពលកម្មធ្ងន់ធ្ងរ បានចំនួន១៧,២៦៤នាក់ (ស្រី៧,៩៧២នាក់) ក្នុងនោះការដកហូតមានចំនួន៨,៩៤២នាក់ (ស្រី២,៥៥៩នាក់) និងធ្វើការបង្ការ-ទប់ស្កាត់ចំនួន៩,៣២២នាក់ (ស្រី៥,៤១៣នាក់) ។

## ឃ- ការលើកកម្ពស់សមត្ថភាព:

### ១. ការបណ្តុះបណ្តាល:

ក្នុងឆ្នាំ២០១១កន្លងទៅនេះ ពិនិត្យលើការងារបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ មន្ត្រីតុលាការ គ្រូបង្គោល លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស មន្ត្រីពាក់ព័ន្ធ អង្គការ សមត្ថកិច្ច ក្រុមប្រឹក្សាឃុំ-សង្កាត់ និង ប្រជាពលរដ្ឋ សរុបធ្វើបានចំនួន៦០០លើក មនុស្ស៥២,១០៨នាក់ (ស្រី១៨,២៩៩នាក់) ក្នុងគោលបំណងពង្រឹងសមត្ថភាព ស្វែងយល់អំពីច្បាប់ពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស ជំនាញឯកទេសចោទប្រកាន់ និងស៊ើបអង្កេត ការវិភាគរឿងក្តីពាក់ព័ន្ធការជួញដូរមនុស្ស និងស្វែងយល់ អំពីល្បិចកលរបស់ជនល្មើស វិធីសាស្ត្រការពារខ្លួននៅពេលមានហេតុការណ៍កើតឡើង ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្សេងៗ អំពើហិង្សាក្នុងគ្រួសារ និងសិទ្ធិកុមារ ក្នុងនោះមាន៖

- ក្រសួងអប់រំយុវជន និងកីឡា បើកវគ្គបណ្តុះបណ្តាលចំនួន១១វគ្គ សរុបបានចំនួន១៧,៦០១នាក់ (ស្រី៨,៤៨២នាក់) ។
- ក្រសួងកិច្ចការនារី សហការអង្គការយៃអន្តរជាតិ IOM UNICEF CDC បានបើកវគ្គបណ្តុះបណ្តាល ចំនួន១៧លើក សរុបបានចំនួន៩៤៣នាក់ (ស្រី៣១៣នាក់) ។
- ក្រុមការងារ COMMIT ដែលដឹកនាំដោយក្រសួងកិច្ចការនារី បានបើកវគ្គចំនួន០៤លើក សរុបបានចំនួន១៩២នាក់ (ស្រី៥៥នាក់) ។
- ក្រសួងយុត្តិធម៌ សហការជាមួយអង្គការ UNIAP, ARTIP, LAC, EVERY CHILD បណ្តុះ-បណ្តាលចំនួន០៥លើក ដល់ចៅក្រម ព្រះរាជអាជ្ញា ក្រុមការងារវិភាគរឿងក្តី មន្ត្រីអង្គការ ចំនួន១៣៥នាក់ ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបណ្តុះបណ្តាលចំនួន០១លើក សរុបបានចំនួន១៣០នាក់ (ស្រី២៧នាក់) ។
- ក្រុមប្រឹក្សាជាតិដើម្បីកុមារ សហការជាមួយសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារ បើកវគ្គបណ្តុះបណ្តាលចំនួន១០លើក សរុបបានចំនួន៣៧៣នាក់ ។
- ក្រសួងទេសចរណ៍ បានបើកវគ្គបណ្តុះបណ្តាល០១លើក សរុបបានចំនួន២៩នាក់ (ស្រី១៧នាក់) ។
- ក្រសួងមហាផ្ទៃ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃ អគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយអង្គការដៃគូ CWCC USAID SISHA IJM LEASETC LEAP ARTIP និងការិយាល័យស៊ើបអង្កេតសហរដ្ឋអាមេរិក បើកវគ្គបណ្តុះបណ្តាលចំនួន១៥លើក ដល់មន្ត្រីនគរបាលអនុវត្តច្បាប់ សរុបបានចំនួន៣៨៦នាក់ (ស្រី៦៥នាក់) ។
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស សហការឧបត្ថម្ភពីគម្រោង ARTIP និង UNIAP បើកវគ្គបណ្តុះបណ្តាល០២លើក ដល់សិក្ខាកាមជាកងរាជអាវុធហត្ថ សរុបបានចំនួន៧៦នាក់ (ស្រី០២នាក់) ។
- អង្គការសកម្មភាពដើម្បីកុមារ បានបើកវគ្គបណ្តុះបណ្តាលបានចំនួន៦១លើក ដល់ក្មេងតាមចញ្ចើមផ្លូវ សិស្សសាលា និងប្រជាពលរដ្ឋ សរុបចំនួន៨៨៧នាក់ (ស្រី៥៣៥នាក់) ពីខេត្តបាត់ដំបង កណ្តាល និងរាជធានីភ្នំពេញ។
- អង្គការស៊ីសា បានបើកវគ្គបណ្តុះបណ្តាលបានចំនួន០២លើក ដល់ប្រជាពលរដ្ឋ សរុបចំនួន១៣០នាក់ (ស្រី៥៦នាក់) នៅក្នុងខេត្តរតនៈគីរី និងមណ្ឌលគីរី ។

NATIONAL COMMITTEE TO LEAD S.T.S.L.

- សម្ព័ន្ធអង្គការ NGO ប្រឆាំងការជួញដូរកុមារមាន: COCD CSF DCO SSO CWCC PAV សហការជាមួយអាជ្ញាធរមូលដ្ឋាន បើកវគ្គបណ្តុះបណ្តាល បានចំនួន០៣លើក ដល់ប្រជាពលរដ្ឋ សរុបបានចំនួន៤១៨នាក់ (ស្រី១៩៨នាក់) ។
- គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្ត បានសហការជាមួយអង្គការដៃគូ ពិសេសអង្គការ AFESIP និងមូលនិធិសុម៉ាលីម៉ម បើកវគ្គបណ្តុះបណ្តាលចំនួន៤៦៨លើក សរុបបានចំនួន៣០,៨០៨នាក់ (ស្រី២២,៧៧៨នាក់) ក្នុងនោះមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| -ខេត្តកណ្តាល | បាន០៥លើក | សរុប៦២១នាក់ | ស្រី៩២នាក់ |
| -ខេត្តបន្ទាយមានជ័យ | បាន០៣លើក | សរុប១៩៩នាក់ | ស្រី២៤នាក់ |
| -ខេត្តសៀមរាប | បាន៦៨លើក | សរុប២,០១៣នាក់ | ស្រី៨៣៦នាក់ |
| -ខេត្តស្វាយរៀង | បាន០២លើក | សរុប៣៦១នាក់ | ស្រី៥៣នាក់ |
| -ខេត្តកំពង់ធំ | បាន០៣លើក | សរុប២៣៧នាក់ | ស្រី១២៨នាក់ |
| -ខេត្តកំពត | បាន១៥១លើក | សរុប១៨,៤១២នាក់ | ស្រី១,៥៨១០នាក់ |
| -ខេត្តព្រះសីហនុ | បាន០៣លើក | សរុប៩៧នាក់ | ស្រី៣០នាក់ |
| -ខេត្តកែប | បាន០៤លើក | សរុប២៣៧នាក់ | ស្រី១៨៧នាក់ |
| -ខេត្តក្រចេះ | បាន០១លើក | សរុប២១នាក់ | ស្រី០៨នាក់ |
| -ខេត្តតាកែវ | បាន០១លើក | សរុប៨៩នាក់ | ស្រី៤០នាក់ |
| -ខេត្តកំពង់ឆ្នាំង | បាន២១៥លើក | សរុប៧,៨១៨នាក់ | ស្រី៥,៥២៥នាក់ |
| -ខេត្តស្ទឹងត្រែង | បាន០១លើក | សរុប៤០នាក់ | ស្រី១៦នាក់ |
| -ខេត្តកំពង់ស្ពឺ | បាន០៤លើក | សរុប៥៥២នាក់ | |
| -ខេត្តកោះកុង | បាន០១លើក | សរុប៥០នាក់ | |
| -ខេត្តបាត់ដំបង | បាន០៣លើក | សរុប៦០នាក់ | ស្រី២៥នាក់ |
| -ខេត្តព្រៃវែង | បាន០៣លើក | សរុប៥១នាក់ | ស្រី០៤នាក់ ។ |

## ២. សិក្ខាសាលា:

ក្នុងឆ្នាំ២០១១កន្លងទៅនេះ ថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត បានសហការជាមួយអង្គការ ដៃគូ បើកវគ្គសិក្ខាសាលា បានចំនួន៣៥វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន២,៤៥១នាក់ (ស្រី៧៩៥នាក់) ដែលបានរៀបចំដោយ៖

- លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ សហការជាមួយអង្គការ IOM និង World Vision អង្គការជំនួយផ្នែកច្បាប់ អង្គការយែរអន្តរជាតិ បើកសិក្ខាសាលា បានចំនួន០៤វគ្គ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ស្តីពីទេសន្តរប្រវេសន៍ការងារ និងការជួញដូរមនុស្ស ស្តីពីការលើកកម្ពស់គុណភាពសេវាកម្ម ច្បាប់សម្រាប់កុមាររងគ្រោះដោយសារការជួញដូរមនុស្ស និងការរំលោភផ្លូវភេទ ព្រមទាំងការពិនិត្យ និងផ្តល់អនុសាសន៍លើសេចក្តីព្រាងចុងក្រោយនៃអនុសញ្ញាអន្តរជាតិ ស្តីពីអ្នកធ្វើការងារតាមផ្ទះ ដោយមានសិក្ខាកាមសរុបចំនួន៣៣១នាក់ (ស្រី១០៤នាក់) ។
- ក្រសួងអប់រំយុវជន និងកីឡា សិក្ខាសាលា បានចំនួន០៣វគ្គ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស ការផ្សព្វផ្សាយផ្ទាំងរូបភាព និងការអនុវត្តន៍សិទ្ធិកុមារ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន៥៩៨នាក់ (ស្រី១២៣នាក់) ។
- ក្រសួងព័ត៌មាន សិក្ខាសាលា០២វគ្គ ក្រោមប្រធានបទ "**បង្កើនការយល់ដឹងពីអំពើជួញដូរមនុស្ស**" ផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងលើបញ្ហាកុមារដល់អ្នកសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី ក្រុមកំប្លែង ពីធីករ/ពីធីការិនី តារាចម្រៀង និងអាយ៉ៃ សរុបចំនួន១៧៥នាក់(ស្រី៤៥នាក់)។

- ក្រសួងទេសចរណ៍ សិក្ខាសាលាចំនួន០១វគ្គ ដើម្បីកសាងសមត្ថភាពដល់ប្រតិបត្តិករទេសចរណ៍ ចំនួន២៣នាក់ ស្តីពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ ។
- ក្រសួងកិច្ចការនារី សហការជាមួយអង្គការឃែរអន្តរជាតិប្រចាំនៅកម្ពុជា UNICEF, UN WOMEN បើកសិក្ខាសាលា បានចំនួន០៩វគ្គ ស្តីពីយេនឌ័រ និងការធ្វើទេសន្តរប្រវេសន៍ការងារ បញ្ហាហិង្សាការរំលោភសេពសន្ថវៈ ការលើកកម្ពស់សុវត្ថិភាពស្ត្រីជានិយោជិកនៅក្នុងឧស្សាហកម្មស្រាបៀរ កិច្ចការពារកុមារ និងការសិក្សាស្រាវជ្រាវបទល្មើសពាក់ព័ន្ធនឹងកុមារ ដោយមានសិក្ខាកាមសរុបចំនួន៤៧២នាក់ (ស្រី៣០៥នាក់) ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បើកសិក្ខាសាលា០១វគ្គ ដើម្បីបំប៉នគ្រូឧទ្ទេសចំនួន២៦នាក់ (ស្រី០៧នាក់) ផ្សព្វផ្សាយគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរ ដើម្បីបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា ឃុំ-សង្កាត់ ។
- ក្រុមប្រឹក្សាជាតិដើម្បីកុមារ បើកសិក្ខាសាលា០១វគ្គ ដើម្បីពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ក្របខ័ណ្ឌច្បាប់ និងកិច្ចការពារកុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានសិក្ខាកាមចូលរួមចំនួន១០៧នាក់ (ស្រី៣២នាក់) ។
- ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី បើកសិក្ខាសាលា០១វគ្គ ដើម្បីផ្សព្វផ្សាយរបាយការណ៍ជាតិលើកទី៤-៥ ស្តីពីការអនុវត្តន៍អនុសញ្ញាស៊ី-ដ នៅកម្ពុជា ពិធីសារ និងអនុសាសន៍១៣ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដោយមានសិក្ខាកាមចូលរួមចំនួន៦៥នាក់ (ស្រី៣០នាក់) ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រសួងអប់រំយុវជន និងកីឡា និងអង្គការ WINROCK International ប្រចាំនៅកម្ពុជា រៀបចំសិក្ខាសាលា០២វគ្គ ដើម្បីពិគ្រោះយោបល់ ស្តីពីពលកម្មកុមារ និងការអប់រំក្នុងវិស័យកសិកម្ម និងមានគោលបំណងធ្វើសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីពលកម្មកុមារ និងការអប់រំដោយមានសិក្ខាកាមចូលរួមចំនួន ៩៥នាក់ (ស្រី១៤នាក់) ។
